**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

លេខ ០០៧១ សសរ. កសក

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការសម្របសម្រួលការងារស្រាវជ្រាវវិទ្យាសាស្ត្រកសិកម្ម របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារ ភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការនិងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្មចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឲ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្មឲ្យទៅជាអគ្គនាយកដ្ឋានកសិកម្មនិងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ ស្តីពីការដំឡើងនាយកដ្ឋានផលិតកម្មនិងបសុព្យាបាលទៅជាអគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ
- បានឃើញអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ ស្តីពីការកែសម្រួលមាត្រា៧ មាត្រា២៥ មាត្រា២៦ និងមាត្រា៣៥ នៃអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ និងមាត្រា២៧ថ្មី នៃអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៧
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតគណៈកម្មការសម្របសម្រួលការងារស្រាវជ្រាវវិទ្យាសាស្ត្រកសិកម្ម របស់ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ ដែលមានសមាសភាពដូចខាងក្រោមៈ

| | | |
|---|---|---|
| ១. ឯកឧត្តម **ឱម គឹមស៊ា** | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ប្រធាន |
| ២. ឯកឧត្តម **ចាន់ ចេស្តា** | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| ៣. ឯកឧត្តម **តូច ប៊ុនហួរ** | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| ៤. លោកជំទាវ **ចាន់ ផលលឿន** | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| ៥. លោកជំទាវ **ឃឿ អាស៊ីគីន** | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| ៦. ឯកឧត្តម **ចាន់ សារុទ្ធ** | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| ៧. ឯកឧត្តម **មាស ពិសិដ្ឋ** | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| ៨. ឯកឧត្តម **ស្រី ទុឡ្សី** | អគ្គលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| ៩. ឯកឧត្តម **កែវ អូម៉ាលីស្ស** | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធានរដ្ឋបាលព្រៃឈើ | សមាជិក |
| ១០. ឯកឧត្តម **ចិន ឆាយ** | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានកសិកម្ម | សមាជិក |
| ១១. ឯកឧត្តម **តាន់ ផាន់ណារ៉ា** | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ | សមាជិក |
| ១២. ឯកឧត្តម **ពុំ សុថា** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាប្រធានរដ្ឋបាលជលផល | សមាជិក |
| ១៣. ឯកឧត្តម **ហ៊ីម អូន** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ | សមាជិក |
| ១៤. ឯកឧត្តម **ខៅ ប៊ុនថាន** | សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម | សមាជិក |
| ១៥. ឯកឧត្តម **ធន់ ចឡ្យនា** | នាយកវិទ្យាស្ថានជាតិកសិកម្មព្រែកលៀប | សមាជិក |
| ១៦. ឯកឧត្តម **ហោម វីរៈ** | នាយកវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម | សមាជិក |
| ១៧. ឯកឧត្តម **ព្រំ សុមានី** | ទីប្រឹក្សាក្រសួងនិងជាប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១៨. លោក **ម៉ឹក គឹមស្រួយ** | អគ្គលេខាធិការរងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១៩. លោក **សរ ចិត្រា** | អគ្គលេខាធិការរងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ២០. លោក **ទី ចាន់ណា** | ប្រធាននាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស | សមាជិកអចិន្ត្រៃយ៍ |
| ២១. លោកស្រី **គង់ សុធីរ៍** | ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ | សមាជិកា |
| ២២. លោក **ជា ច័ន្ទវាសនា** | ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល | សមាជិក |
| ២៣. លោក **តុំ រ៉ា** | ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម | សមាជិក |
| ២៤. លោក **ម៉ក់ ម៉ូនី** | ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ | សមាជិក |
| ២៥. លោក **ឡោ ប៊ុណ្ណា** | នាយកវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា | សមាជិក |
| ២៦. លោក **លិម ខាន់ទីវ៉ា** | នាយកវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | សមាជិក |
| ២៧. លោក **អ៊ុំ សាវី** | អនុប្រធាននាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស | លេខាធិការ |
| ២៨. លោក **គឹម ចាន់ខោត** | អនុប្រធានការិយាល័យនៃនាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស | លេខាធិការ |

**ប្រការ២ .-**

គណៈកម្មការនេះ មានភារកិច្ចដូចខាងក្រោមៈ

- រៀបចំកសាងនិងដាក់ចេញឱ្យអនុវត្តគោលនយោបាយស្រាវជ្រាវកសិកម្មកម្ពុជា និងពិនិត្យ វាយតម្លៃការអនុវត្តគោលនយោបាយនេះឱ្យទទួលបានប្រសិទ្ធភាពខ្ពស់

- ដឹកនាំ និងសម្របសម្រួលការងារស្រាវជ្រាវកសិកម្មឱ្យមានលក្ខណៈប្រទាក់ក្រឡាគ្នាពេញលេញ បង្កើនកិច្ចសហការរវាងអង្គភាពស្រាវជ្រាវកសិកម្ម ដើម្បីធានាបាននូវសង្គតិភាពនៃការងារកសាងនិងអនុវត្តផែនការស្រាវជ្រាវកសិកម្មប្រកបដោយគុណភាព តម្លាភាព និងឆ្លើយតបទៅនឹងតម្រូវការប្រើប្រាស់បច្ចេកវិទ្យាកសិកម្មទំនើប
- រៀបចំ សម្របសម្រួល ពិនិត្យនិងផ្តល់យោបល់នូវរាល់កម្មវិធី ឬគម្រោងសំណើស្រាវជ្រាវកសិកម្មនានាពីអង្គភាពស្រាវជ្រាវកសិកម្មក្រោមឱវាទក្រសួង សំដៅជំរុញការអភិវឌ្ឍអនុវិស័យនីមួយៗក្នុងវិស័យកសិកម្មឱ្យមាននិរន្តរភាព និងប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់
- សម្របសម្រួលការពង្រឹងសមត្ថភាពធនធានមនុស្ស ជំនាញវិជ្ជាជីវៈសម្រាប់ការងារស្រាវជ្រាវវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ក្នុងវិស័យកសិកម្មឱ្យបានគ្រប់គ្រាន់ មានសមត្ថភាព និងគុណវុឌ្ឍិខ្ពស់ ដើម្បីចូលរួមក្នុងដំណើរការទំនើបកម្មវិស័យកសិកម្ម
- សម្របសម្រួលលើការងារជំរុញការផ្សព្វផ្សាយចំណេះដឹង ជំនាញ និងលទ្ធផលស្រាវជ្រាវវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍វិស័យកសិកម្ម
- ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការលើការងារស្រាវជ្រាវកសិកម្មជាមួយស្ថាប័នស្រាវជ្រាវជាតិ និងអន្តរ-ជាតិ និងពង្រីកឱ្យបានទូលំទូលាយនូវកិច្ចសហការក្នុងភាពជាដៃគូរវាងរដ្ឋ វិស័យឯកជន ដៃគូអភិវឌ្ឍ និងសហគមន៍មូលដ្ឋានលើការងារស្រាវជ្រាវ និងអភិវឌ្ឍន៍វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ក្នុងវិស័យកសិកម្ម
- សម្របសម្រួលនិងសហការការងារជាមួយក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ធ្វើរបាយការណ៍វឌ្ឍនភាពនៃការងារស្រាវជ្រាវវិទ្យាសាស្ត្រកសិកម្ម ជូនឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ
- អនុវត្តភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំប្រគល់ឲ្យ។

**ប្រការ៣.-**

គណៈកម្មការនេះ មានក្រុមការងារបច្ចេកទេស ជាជំនួយការ ដែលមានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| ១. ឯកឧត្តម **ចាន់ សារុន្ធ** | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ប្រធាន |
| ២. លោកជំទាវ **យ៉ើ អាស៊ីគីន** | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| ៣. លោក **សរ ចិត្រា** | អគ្គលេខាធិការរង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| ៤. លោក **សុខ ហេង** | ប្រធានវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍ព្រៃឈើ សត្វព្រៃ នៃរដ្ឋបាលព្រៃឈើ | សមាជិក |
| ៥. លោក **ឈួន ចំណាន** | ប្រធាននាយកដ្ឋានបច្ចេកវិទ្យាកែច្នៃ និងគុណភាព នៃរដ្ឋបាលជលផល | សមាជិក |
| ៦. លោក **ទុំ សុធីរ៉ា** | ប្រធានវិទ្យាស្ថានស្រាវជ្រាវសុខភាពសត្វនិងផលិតកម្មសត្វ នៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ | សមាជិក |
| ៧. លោក **នូ វនិកា** | ប្រធាននាយកដ្ឋានសុខភាពសត្វ និងសុខភាពសាធារណៈ បសុព្យាបាល នៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ | សមាជិក |
| ៨. លោក **គង់ គា** | ប្រធាននាយកដ្ឋានដំណាំស្រូវ នៃអគ្គនាយកដ្ឋានកសិកម្ម | សមាជិក |
| ៩. លោក **សេង វ៉ាង** | ប្រធាននាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម | សមាជិក |
| ១០. លោក **ម៉ុនតុង បូរារិន** | នាយកផ្នែកស្រាវជ្រាវ និងផ្សព្វផ្សាយ នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម | សមាជិក |
| ១១. លោក **ប៉ុល ចាន់ធី** | នាយករងវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា | សមាជិក |

១២. លោក **ហ៊ិន សារិត** នាយករងវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា សមាជិក

១៣. លោក **ហុក លីដា** ព្រឹទ្ធបុរសរងមហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម សមាជិក

១៤. លោក **ឈុន ឥទ្ធី** ប្រធានដេប៉ាតឺម៉ង់វិទ្យាសាស្ត្រកសិកម្ម នៃវិទ្យាស្ថានជាតិកសិកម្មព្រែកលៀប សមាជិក

**ប្រការ៤ ._**

ក្រុមការងារបច្ចេកទេស នៃគណៈកម្មការនេះ មានភារកិច្ច ដូចខាងក្រោម ៖

- តាមដានការអនុវត្តគោលនយោបាយស្រាវជ្រាវកសិកម្មកម្ពុជាដើម្បីរាយការណ៍ជូនគណៈកម្មការសម្របសម្រួលការងារស្រាវជ្រាវវិទ្យាសាស្ត្រកសិកម្ម របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- រៀបចំគម្រោងសំណើស្រាវជ្រាវកសិកម្មនានា ជូនគណៈកម្មការសម្របសម្រួលការងារស្រាវជ្រាវវិទ្យាសាស្ត្រកសិកម្ម របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីពិនិត្យ និងស្នើសុំទៅដៃគូរអភិវឌ្ឍ
- ពិនិត្យ តាមដាន ផ្តល់មតិ និងរាយការណ៍ជូនគណៈកម្មការសម្របសម្រួលការងារស្រាវជ្រាវវិទ្យាសាស្ត្រកសិកម្ម របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បី ជំរុញការងារបោះពុម្ពផ្សាយ និងផ្សព្វផ្សាយលទ្ធផលការងារស្រាវជ្រាវកសិកម្ម
- ពិនិត្យនិងផ្តល់មតិលើសំណើ ឬលទ្ធផលនៃការងារស្រាវជ្រាវវិទ្យាសាស្ត្រកសិកម្ម របស់អង្គភាពជំនាញនានាក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- អនុវត្តភារកិច្ចផ្សេងទៀតដែលគណៈកម្មការប្រគល់ឲ្យ។

**ប្រការ៥ ._**

គណៈកម្មការនេះ មានសិទ្ធិប្រើថវិការបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងប្រភពថវិកាស្របច្បាប់ផ្សេងៗទៀត ដើម្បីដំណើរការការងាររបស់ខ្លួន។

គណៈកម្មការនេះ មានសិទ្ធិស្វែងរកដៃគូអភិវឌ្ឍឬផ្នែកឯកជន ដើម្បីជួយទ្រទ្រង់និងឧបត្ថម្ភបន្ថែមដល់ដំណើរការការងារស្រាវជ្រាវវិទ្យាសាស្ត្រកសិកម្ម។

**ប្រការ៦ ._**

អគ្គលេខាធិការ អគ្គាធិការ ប្រធាននាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធានគ្រប់អង្គភាពដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ៧កើត ខែ មាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃ ០៨ ខែ កុម្ភៈ ឆ្នាំ២០២២

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ក្រសួងមុខងារសាធារណៈ
- ដូចប្រការ៦
- ឯកសារ កាលប្បវត្តិ